# ឧបករណ៍ដើម្បីអភិវឌ្ឍផែនការមីក្រូ

បញ្ជីនៃឧបករណ៍ទាំងនេះ គឺសម្រាប់តែបង្ហាញ និង អាចប្រើប្រាស់ ដើម្បីជាជំហានតាមសេចក្តីត្រូវការនៃបរិបទ និង បញ្ហា ។

## ជំហានទី ១

**ដំណើរកាត់តទឹង : បង្កើតការប្រាស្រ័យទាក់ទងល្អ ជាមួយសហគមន៍ និង ត្រួតពិនិត្យមើលនូវអ្វីដែលបានពិភាក្សា ក្នុងការប្រជុំក្រុម**

រើសយកក្រុមស្ម័គ្រចិត្តចេញពីក្នុងសហគមន៍ ដើម្បីដើរកាត់ភូមិ / Gram Panchayat (ក្រុមប្រឹក្សាភូមិ) ។ សួរទៅអ្នកស្ម័គ្រចិត្តម្នាក់ៗ ដើម្បីឱ្យគាត់សង្កេតទៅលើបញ្ហាជាក់លាក់ ដែលទាក់ទងនឹងការធ្វើផែនទីធនធាន ឬ ផែនទីសង្គម ដែលកិច្ចការនេះអាចត្រូវធ្វើមុន ឬ ធ្វើនៅក្រោយពេលដើរក៏បាន ។ ស្នើឱ្យម្នាក់ៗកត់ត្រា ឬ ធ្វើរួមគ្នាជាមួយអ្នកដែលអាចកត់ត្រានូវការសង្កេតបាន ។ ពោលគឺកំណត់អត្តសញ្ញាណនៃបញ្ហា ឱ្យបានទូលំទូលាយ ជាពិសេសគឺអ្វីដែលទាក់ទងនឹងដីធ្លី ។

**ពេលវេលា : កត់ត្រាអំពីប្រវត្តិភូមិ និង ណែនាំប្រជាជនឱ្យបានយល់ព្រមទាំងកំណត់នូវសាច់រឿង និង គំរូនានា ដែលមានឥទ្ធិពលទៅលើសហគមន៍ :**

បញ្ហានេះ នឹងបង្កើតនូវបរិបទ សម្រាប់គោលបំណងរួមដែលអាចជួយអ្នក ក្នុងការបង្កើតឱ្យមានអ្វីៗផ្សេងទៀត ។ ឧបករណ៍នេះ ត្រូវប្រើក្នុងដំណាក់កាលទី ១ នាអំឡុងពេលបង្ហាញ ឬ នាអំឡុងពេលដែលអ្នកជួបប្រជុំជាមួយក្រុមផ្សេងទៀត ។

- ចែកក្រដាសផ្ទាំងធំ និង ប៊ិចសរសេរដល់ប្រជាជន បន្ទាប់មកបែងចែកពួកគាត់ទៅតាមក្រុមប្រភេទអាយុ ឬ ប្រភេទបញ្ហាផ្សេងៗ ដូចជាការអភិវឌ្ឍរបស់ក្រុមប្រឹក្សាភូមិ Panchayats ឬការគ្រប់គ្រងទឹក ឬ ទីជម្រាលបង្ហូរទឹកជាដើម ។
- ពន្យល់ថាយើងនឹងកត់ត្រាប្រវត្តិ តាមដែលយើងចងចាំ ដើម្បីធ្វើការកត់ត្រាអំពីការអភិវឌ្ឍភូមិ ។
- ក្រុមនីមួយៗបង្កើតជាតារាងពេលវេលា ។ ហើយតារាងពេលវេលាទាំងអស់ត្រូវប្រមូលផ្តុំគ្នានៅលើក្រដាសផ្ទាំងធំមួយ ។

- ចែករំលែកជីវប្រវត្តិជាក់ស្តែង ដោយបិទវានៅលើជញ្ជាំង ដើម្បីធ្វើការកត់សម្គាល់អំពីចំណុចសំខាន់ៗ សម្រាប់ការអភិវឌ្ឍនៅក្នុងភូមិ និង ដើម្បីស្វែងយល់ពីអ្វីៗដែលបានកើតឡើង នាពេលអតីតកាល ។

## ជំហានទី ២

### ទំនាក់ទំនងម៉ាទ្រិច : យល់អំពីទំនាក់ទំនងដែលមានស្រាប់ក្នុងភូមិ

ខណៈពេលដែលធ្វើការអភិវឌ្ឍផែនការមីក្រូ លោក-អ្នកចាំបាច់ត្រូវប្រយ័ត្នប្រយែង ក្នុងការលៃលកជួបជាមួយគ្រប់តំណាងតាមលំដាប់ថ្នាក់ វណ្ណៈ និង អាយុ ។ អ្នកគ្មានអំណាច និង អ្នកមានអំណាច គប្បីមានឥទ្ធិពលស្មើៗគ្នានៅក្នុងភូមិ ក្នុងការធ្វើផែនការមីក្រូនេះ ។ ប្រសិនបើអ្នកមាន ប្រើឥទ្ធិពលមកលើអ្នកតែម្នាក់នោះ អ្នកក្រនឹងត្រូវកាត់ផ្តាច់ចេញពីដំណើរការ ហើយផ្ទុយមកវិញ ។ ខ្សែបណ្តាញទំនាក់ទំនង នឹងផ្តល់ឱ្យក្រុមអ្នកចូលរួមក្នុងកិច្ចប្រជុំបានដឹងថា តើអ្នកណាមានទំនាក់ទំនងទៅនឹងអ្នកណាក្នុងភូមិ និង ដោយមូលហេតុអ្វី ។ ចំណុចនេះ ក៏ផ្តល់ជាដំណឹងថា តើក្រុមណាដែលពុំមានភាពជិតស្និទ្ធនឹងគ្នា ។ ពេលធ្វើផែនការ ព័តិមាននេះនឹងមានសារៈប្រយោជន៍ ដើម្បីដាក់ឱ្យស្មើគ្នានូវសេចក្តីត្រូវការចាំបាច់ និង តម្រូវការនៃក្រុមផ្សេងៗក្នុងភូមិ ដោយផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងដែលមានស្រាប់ ។

ដ្យាក្រាមខាងក្រោមនេះ បង្ហាញឱ្យឃើញផ្ទាល់ អំពីទំនាក់ទំនង និង តួនាទីនៃវណ្ណៈក្រុម ។ នេះក៏បង្ហាញអំពីគំរូលំដាប់ថ្នាក់/វណ្ណៈ នៅក្នុងភូមិផងដែរ ។ ក្រុមវណ្ណៈនីមួយៗ មានទំនាក់ទំនងជិតស្និទ្ធ ជាមួយគ្នាទៅវិញទៅមកដែលជាការចែករំលែក នូវទំនាក់ទំនងសេដ្ឋកិច្ច-សង្គម ។




ដ្យាក្រាមបង្ហាញអំពីទំនាក់ទំនងម៉ាទ្រិចក្នុងភូមិ

ទំនាក់ទំនងម៉ាទ្រិចនេះ បង្ហាញអំពីទំនាក់ទំនងដែលមានស្រាប់ និងគម្លាតពីគ្នាទៅវិញទៅមក ។ លោក-អ្នកអាចចាប់ផ្ដើមធ្វើការពិភាក្សា ដោយសួរថា តើនរណាមានឥទ្ធិពល ហើយហេតុអ្វី? ។ វាមានប្រយោជន៍ណាស់ ក្នុងការស្គាល់អំពីស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ប្រជាជន ឬ សហគមន៍ និង ទំនាក់ទំនងរវាងក្រុម ឬ មនុស្សផ្សេងៗគ្នា ដើម្បីធ្វើផែនការឱ្យបានល្អប្រសើរថែមទៀត ។ ការវិភាគបន្តទៅទៀត អាចត្រូវបានបន្ថែម ដោយសួរថា តើនរណាត្រូវបានគេជ្រើសរើស ហើយហេតុអ្វី? ។ ការវិភាគនេះ នឹងជួយដល់លោក-អ្នកក្នុងការបង្កើតបាននូវការយល់ដឹងរួម ស្ដីអំពីការចូលរួមរបស់ប្រជាជន និងការកសាងបាននូវទំនាក់ទំនង ដែលជាផលប្រយោជន៍ទៅវិញទៅមករវាងមនុស្សក្នុងក្រុម និង អ្នកតំណាងដែលត្រូវបានជ្រើសរើស ។

## ការគូរផែនទីសង្គម : បង្កើតផែនទីនៃទ្រព្យសម្បត្តិសង្គម

តាមរយៈការប្រើប្រាស់ផែនទីសង្គម យើងអាចប្រមែប្រមូលព័ត៌មាន ស្ដីអំពីចំនួនប្រជាជនក្នុងភូមិ ថាតើមានប្រជាជនប៉ុន្មាននាក់/ប៉ុន្មានគ្រួសារ មានផ្ទះប៉ុន្មានខ្នង និង មានការកាន់កាប់ដីធ្លីយ៉ាងដូចម្ដេច? ។ តើមានប្រជាជនប៉ុន្មាននាក់ដែលពុំមានដីធ្លីរស់នៅ ។ តើមានប្រជាជនប៉ុន្មាននាក់រស់នៅផ្ទះថ្ម ហើយប៉ុន្មាននាក់រស់នៅផ្ទះស្បូវ និង ផ្ទះបិទដី? ។ វាក៏អាចឱ្យយើងដឹងអំពីទំហំបរិយាកាសជុំវិញ ក៏ដូចជាសេវានានាដែលអាចរកបានសម្រាប់ក្រុមមនុស្សផ្សេងៗគ្នាទាំងនោះ ផងដែរ ។

- សុំឱ្យសមាជិកសហគមន៍ គូរផែនទីភូមិនៅលើដី ឬនៅលើសន្លឹកក្រដាស ។ ប្រជាជនច្រើននាក់អាចមើលផែនទីឃើញ ប្រសិនបើវាមានទំហំធំ ។ ដូចនេះ វាជាការប្រសើរ គប្បីគូរវានៅលើដី ប៉ុន្តែកុំភ្លេចចម្លងវាចូលទៅក្នុងក្រដាសមួយផ្ទែកម្ដងៗ ។
- លោក-អ្នកអាចប្រើគ្រួស ឬមែកឈើតូចៗ ធ្វើជាកំណត់ចំណាំនៃផែនទី ដែលបានគូររួចនៅលើដី និង ប្រើខ្មៅដៃពណ៌ ព្រមទាំងដៅជាចំណុចៗ ប្រសិនបើគូរនៅលើក្រដាស។
- អ្នកចូលរួមមានភារៈទទួលខុសត្រូវក្នុងការគូរផែនទី ។ ពោលគឺ គេអាចចាប់ផ្ដើមគូរផ្លូវធំដែលចេញពីផ្ទះមុនគេ បន្ទាប់មកគូរផ្ទះ វាលស្រែចំការ និង ទីកន្លែងផ្ដល់សេវាផ្សេងៗទៀតដែលគេប្រើប្រាស់ ។
- បន្ទាប់មក ស្នើសុំឱ្យប្រជាជនគូសសំគាល់នូវហេដ្ឋារចនាសម្ព័ន្ធមានក្នុងភូមិ ដែលគេពុំបានប្រើប្រាស់វាជាញឹកញាប់ រួមមានផ្លូវថ្នល់ ផ្លូវលំ ប្រឡាយ អណ្ដូងស្នប់ដៃ អណ្ដូងទឹក បណ្ដាញអគ្គិសនី ឱសថាល័យ សាលារៀន ជាដើម ។ល។
- ធនធានរួម និង បង្គោលសីមា ដូចជាវាលស្មៅ ព្រះវិហារ និងត្រពាំងទឹកអាចបូកបន្ថែមបាន ។

- ផ្ទះប្រជាជនក្នុងភូមិ ដែលពុំមានមនុស្សរស់នៅ និង វាលស្រែចំការរបស់គេ ក៏អាចដាក់សញ្ញាសំគាល់ផងដែរ ។
- បន្ថែមព័តិមាន ស្តីអំពីមុខរបររបស់ប្រជាជន ដែលកំពុងរស់នៅតាមក្រុមផ្សេងៗគ្នា ។
- លោក-អ្នកអាចសាកសួរនូវព័តិមានបន្ថែម អំពីភាពដែលអាចរកបាន និង សិទ្ធិទទួលបាននូវសេវាសាធារណៈ ឬ ព័តិមានពាក់ព័ន្ធឯទៀត ដែលចាំបាច់សម្រាប់ជាការដោះស្រាយបញ្ហារួម ដែលកំពុងធ្វើការពិភាក្សា ។
- ផ្ទៀងផ្ទាត់ទិន្នន័យដែលបង្កើតចេញពីរបាយការណ៍ជំរឿន និង ពីអ្នកដទៃផ្សេងទៀតដែលពុំមានវត្តមាន នៅក្នុងកំឡុងពេលគូរផែនទី ។

អ្នកមិនចេះអក្សរ និង ក្មេងតូចៗក៏អាចគូរផែនទីបានដែរ ។ នៅក្នុងផែនទីនេះ លោក-អ្នកអាចបំពេញព័តិមានទាំងអស់ អំពី Panchayat (ភូមិ) របស់លោក-អ្នក។



Report on Drought Based Micro Plan at Panchayat Level, May-June 2001, Prepared by SAMARTHAN, Madhya Pradesh

ដ្យាក្រាមនៃការគូរផែនទីសង្គម

ប្រសិនបើលោក-អ្នកចង់បានព័តិមានបន្ថែម អំពីក្រុមនៃប្រជាជនជាក់លាក់ណាមួយនោះ លោក-អ្នកអាចសួរសំណួរ និងកត់ត្រានូវចម្លើយលើក្រដាសតូចៗ រួចហើយបិទវាលើផែនទី នៅត្រង់កន្លែងដែលវាតាំងនៅ ។

ប្រើប្រាស់សញ្ញាសម្គាល់ផែនទី ដើម្បីបង្ហាញព័ត៌មាន ។ កុំភ្លេចធ្វើតារាងបង្ហាញសញ្ញាសម្គាល់ទាំងអស់ដែលអ្នកបានប្រើ ដោយបិទ ឬ គូរវា នៅជ្រុងណាមួយនៃផែនទី សម្រាប់ទុកជាសេចក្តីបញ្ជាក់របស់ប្រជាជន ។

## ជំហានទី ៣

### ការវិភាគលើភាគីពាក់ព័ន្ធ : ស្គាល់អំពីមនុស្សសំខាន់ៗនៅក្នុង *Panchayat* (ភូមិ)

មុន ឬ នៅក្នុងអំឡុងពេលវគ្គទី ១ នៃអង្គសិក្ខាសាលាណែនាំ លោក-អ្នកអាចចង់ដឹង អំពីមនុស្សសំខាន់ៗក្នុង Panchayat (ភូមិ) ។ អ្នកទាំងនេះ ត្រូវបានគេស្គាល់ថា ជាសមាជិកនៃភាគីដែលពាក់ព័ន្ធ ក្នុងសហគមន៍ភូមិ ។ ឧបករណ៍នេះ រៀបចំភាគីពាក់ព័ន្ធទាំងអស់ ក្នុងផែនការមីក្រូ ដើម្បីពិនិត្យមើលថា តើពួកគេមានទំនាក់ទំនងជិតស្និទ្ធយ៉ាងណា ព្រមទាំងបញ្ជាក់ឱ្យដឹងឡើងវិញអំពីទំនាក់ទំនងជិតស្និទ្ធ ក្នុងកិច្ចដំណើរការនៃការធ្វើផែនការមីក្រូនេះ ។

កំណត់ឱ្យបានច្បាស់នូវភាគីពាក់ព័ន្ធ មុននឹងដំណើរការធ្វើផែនការមីក្រូ ដោយហេតុថា ភាគីពាក់ព័ន្ធនឹងជាអ្នកដែលត្រូវធ្វើផែនការដោយខ្លួនគេផ្ទាល់ ។ សមាជិកនៃ Gram Sabha (សន្និបាតភូមិ) ចាំបាច់ត្រូវចូលរួមជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ Mahila Mandals (ក្រុមស្ត្រី) និងក្រុមយុវវ័យ នៅដំណាក់កាលដំបូង ។

- លោក-អ្នកត្រូវបង្ហាញទាំងឥទ្ធិពល និង ការជឿទុកចិត្ត តាមរយៈការជួបប្រជុំជាមួយបុគ្គលណាម្នាក់ ដោយផ្ទាល់ជាមុន ក្នុងករណីចាំបាច់លោក-អ្នកត្រូវធ្វើឱ្យបានច្រើនលើក រហូតទាល់តែបានដឹងនូវតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍរបស់ពួកគេ ។ បន្ទាប់មក ភាគីពាក់ព័ន្ធមកជួបប្រជុំគ្នា ដើម្បីបង្ហាញអំពីសេចក្តីត្រូវការចាំបាច់រួមរបស់ខ្លួន ។
- ធ្វើចំណាត់ថ្នាក់ចំពោះភាគីពាក់ព័ន្ធ :
  - ➢ ភាគីពាក់ព័ន្ធដែលអាចប៉ះពាល់ដោយផ្ទាល់ដូចជា សហគមន៍ ចាស់ទុំក្នុងភូមិ ស្ត្រី និងកុមារ កុលសម្ព័ន្ធ (ក្រុមជនវណ្ណៈ ឬត្រកូលទាប ក្នុងសង្គម...), ជនពិការ និង
  - ➢ ភាគីពាក់ព័ន្ធដែលអាចប៉ះពាល់ដោយប្រយោលរួមមាន Gram Sevaks (លេខានៃក្រុមប្រឹក្សាភូមិ) បុគ្គលិកផ្នែកដែលពាក់ព័ន្ធ គ្រូបង្រៀន anganwadi (មជ្ឈមណ្ឌលថែទាំកុមារ) និងបុគ្គលិកមណ្ឌលសុខភាព ។
- កំណត់គោលដៅ និង គោលបំណង នៃការធ្វើផែនការសម្រាប់ក្រុមប្រជាជននីមួយៗ ។
- សួរក្រុមភាគីពាក់ព័ន្ធនីមួយៗ អំពីបញ្ហា និង ការរំពឹងទុកដែលទទួលបានតាមរយៈការធ្វើផែនការ ផលប្រយោជន៍ពីការធ្វើផែនការ ការធ្វើវិភាគទានធនធានដែលមានស្រាប់ និង ក្តី

វិពឹងទុកពីសហគមន៍ ក្នុងការដោះស្រាយបញ្ហា ។ ប្រសិនបើមានទំនាស់ផលប្រយោជន៍កើតឡើងនោះ គប្បីស្វែងរកដំណោះស្រាយដោយសន្តិវិធីតាមដែលអាចធ្វើបាន ។

## ការធ្វើផែនទីធនធាន : ស្គាល់អំពីធនធានអ្វីដែលមាននៅក្នុងភូមិ

ឧបករណ៍នេះ ជួយដល់ការធ្វើផែនការឱ្យបានងាយស្រួល ដោយយើងដឹងនូវអ្វីដែលយើងមាន ដូចនេះហើយ យើងអាចរៀបចំផែនការ ទៅតាមធនធានដែលមាន ។ នេះក៏អាចជួយឱ្យយើង កំណត់បានច្បាស់នូវធនធានដែលនៅខ្វះចន្លោះ ។ ផែនទីដែលលោក-អ្នកគួរចេញពីឧបករណ៍នេះ អាចប្រើបានជាបន្តបន្ទាប់នូវរាល់តំណាក់កាលនៃការធ្វើផែនការមីក្រូ ។

ប្រសិនបើលោក-អ្នកត្រូវការសាងសង់សាលារៀនមួយខ្នង ប្រហែលជាសំភារៈសំណង់ដែលមានស្រាប់ដូចជា ខ្សាច់ ថ្មដែលយកពីទន្លេ ឬស្ទឹងក្បែរៗនេះ ។ ការធ្វើផែនទីធនធាន នឹងអាចជួយលោក-អ្នកផងដែរ ក្នុងការកំណត់ និងការកត់ត្រាឱ្យបានច្បាស់លាស់ នូវធនធានទាំងអស់ ដូច្នេះពេលខ្លះ គេពុំចាំបាច់រកប្រភពថវិកាពីខាងក្រៅឡើយ ។ បើកាលណាដឹងថា មានធនធានអាចរកបាន ក្នុងភូមិPanchayatនោះ លោក-អ្នកអាចជ្រើសរើសថា តើធនធានមួយណា មានប្រយោជន៍ សម្រាប់ការធ្វើផែនការមីក្រូ ។

ដំបូងលោក-អ្នកចាំបាច់រៀបចំជាបញ្ជីថា តើធនធានអ្វីដែលត្រូវការចាំបាច់ សម្រាប់ការធ្វើផែនការមីក្រូ ។ លោក-អ្នកអាចធ្វើបែបនេះ នៅជំហានទី ៦ ដែលបញ្ហានីមួយៗពាក់ពន្ធ័ទៅនឹងដំណោះស្រាយ សុទ្ធតែត្រូវការធនធាន ។ ទាំងនេះអាចជាធនធានពលកម្ម ធនធានសម្របសម្រួល ធនធានសម្ភារ ដូចជាឈើ ថ្ម និងទឹកដែលអាច រកបាននៅក្នុងភូមិ ឬជាធនធានហិរញ្ញវត្ថុ ដែលខ្លះអាចរកបាននៅតាមអង្គសន្និបាតភូមិ (Gram Sabha) និង ធនធានខ្លះទៀតចាំបាច់ត្រូវលើកឡើង ដើម្បីស្នើសុំ ។

- មនុស្សម្នាក់មិនអាចកំណត់ឱ្យបានច្បាស់លាស់ នូវធនធានទាំងអស់នោះទេ ។ ដូចនេះ វាចាំបាច់ត្រូវអង្គុយជជែកពិភាក្សា ជាមួយសហគមន៍ រួចហើយគូរចេញនូវធនធានចម្បងៗដែលមាននៅក្នុងតំបន់ ។
- វា មានប្រយោជន៍ ក្នុងការគូរចេញនូវធនធានទាំងឡាយ នៅលើផែនទីភូមិខ្លួនឯង ។ នេះអាចមានរួមបញ្ចូលទាំងធនធានធម្មជាតិ វត្ថុសង្គមសម័យបុរាណ ក៏ដូចជាអាគារផ្សេងៗ ដែលមាននៅក្នុង *Panchayat* ឬ ភូមិ ។ លោក-អ្នកអាចគូរចេញនូវធនធាន ដែលមាននៅលើផែនទីភូមិ ដោយប្រើពណ៌តែមួយប្រភេទ ។

- ប្រើបិចពណ៌មួយប្រភេទទៀត ដើម្បីសម្គាល់នូវធនធានណាដែលត្រូវការចាំបាច់ ។ ឧទាហរណ៍ ដូចជា តើទីកន្លែងណា ដែលត្រូវសាងសង់ទំនប់ទឹកតូចៗ ដើម្បីស្តុកទឹកភ្លៀង ឬ ដីនៅទីកន្លែងណាចាំបាច់ត្រូវការចាក់បំពេញដីមានជីជាតិ សម្រាប់អាចប្រកបរបរកសិកម្មបាន ។ លោក-អ្នកអាចដាក់បញ្ចូលក្នុងផែនទីនូវទីកន្លែងសម្រាប់សាងសង់អណ្តូងថ្មី ឬ កំណត់ឱ្យបានច្បាស់លាស់នូវដីធ្លី សម្រាប់ធ្វើការបែងចែកឡើងវិញ ទៅឱ្យអ្នកដែលគ្មានដីរស់នៅ និងអ្នកដែលទីទ័លក្រ ។
- លោក-អ្នកអាចប្រើផែនទីធនធាន ដើម្បីបំពេញបង្គ្រប់ផែនទីសង្គមរបស់ភូមិ ឬប្រើផែនទីតែមួយ សម្រាប់ទាំងពីរ ។ វិធីនេះអាចធ្វើឱ្យលោក-អ្នកចាំបានជានិច្ចថា តើអ្នកណាកំពុងរស់នៅទីណា ហើយតើកំពុងខ្វះខាតធនធានអ្វីខ្លះ និង មានឱកាសទទួលបានធនធានអ្វីខ្លះ ។

### ការធ្វើផែនទីសេវា ៖ ឧបករណ៍នេះ គឺជាសំណុំរងនៃការធ្វើផែនទីធនធាន

ក្នុងករណីដែលដំណើរការរៀបចំផែនការមីក្រូរបស់លោក-អ្នក ទាក់ទិននឹងការពង្រឹងគុណភាពឱ្យប្រសើរឡើង និងអាចទទួលបាននូវសេវាទាំងនោះ លោក-អ្នកនឹងត្រូវយកចិត្តទុកដាក់លើការគូរផែនទីសេវាដែលមានស្រាប់ ។

## ជំហានទី ៤ និង ទី ៥

### ការវិភាគបញ្ហា និង ការស្វែងរកដំណោះស្រាយ តាមរយៈដ្យាក្រាមដើមឈើ ៖ កំណត់ឱ្យបានច្បាស់នូវទំនាក់ទំនងរវាងហេតុ និង ផល ឬ បញ្ហា និង ដំណោះស្រាយ

នេះអាចប្រើនៅដំណាក់កាលទី ២ និង ទី ៣ ពេលមានកិច្ចប្រជុំនៅមណ្ឌល/សង្កាត់ ។ នៅត្រង់នេះគប្បីសួរប្រជាជន ដើម្បីរៀបចំធ្វើបញ្ជីបញ្ហា ។ ដ្យាក្រាមខាងក្រោមនេះ បង្ហាញនូវបញ្ហានៃការជួញដូរស្ត្រីពីក្នុងភូមិ ។ បញ្ហាជាច្រើនអាចលើកយកមកពិនិត្យ ប៉ុន្តែបញ្ហានីមួយៗ គប្បីដោះស្រាយជាលក្ខណៈបុគ្គល ទៅតាមដំណោះស្រាយ សមហេតុផលរបស់វា ។ ការធ្វើបញ្ជីបញ្ហាមានសារៈសំខាន់ ព្រោះវាអាចជួយឱ្យប្រជាជនចងចាំបាននូវជំហានសមហេតុផល ក្នុងការដោះស្រាយបញ្ហានីមួយៗ ។

- សុំឱ្យអ្នកដែលចូលរួមរៀបរាប់អំពីទំនាក់ទំនងរវាងហេតុ-ផល ដោយផ្ទាល់មាត់ ឬ ដោយសង្កេតមើលជាក់ស្តែង ដើម្បីពន្យល់អំពីភាពទាក់ទង ក្នុងចំណោមកត្តាផ្សេងៗគ្នា ដោយលើកយកដើមឈើធ្វើជាឧទាហរណ៍ ។

- លើកឡើងអំពីបញ្ហា រួចហើយសរសេរវា ជារង្វង់នៅក្នុងឫស ។ ឫស ក្តោបនូវបញ្ហាដែលមានស្រាប់ និង បង្កឱ្យមានទ្រង់ទ្រាយឡើង ព្រមទាំងកំណត់នូវឥរិយាបថរបស់ប្រជាជនចំពោះគ្នាទៅវិញទៅមក រួមទាំងការចែករំលែកនូវធនធានផងដែរ ។ ស្ត្រីពុំអាចទទួលបាននូវការប្រើប្រាស់ធនធានឡើយ ។ អ្វីទាំងនេះអាចបង្ហាញថា ជាប្រភពនៃបញ្ហាក្នុងការជួញដូរមនុស្ស ហើយពួកគេត្រូវប្រឈមមុខទៅនឹងអំពើហិង្សា ដែលនៅទីបញ្ចប់ ភាពទីទ័លក្រអាចមានចំពោះពួកគេ ។ ឧបករណ៍នេះ ជួយដាក់បញ្ចូលនូវរាល់ផ្នែកទន់ខ្សោយនានា ដើម្បីចូលរួមក្នុង ដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដែលអាចឈានទៅរកការកសាងដំណោះស្រាយ ។
- ដើមឈើពណ៌នាអំពីដំណោះស្រាយ ។ សរសេរដំណោះស្រាយលើដើមឈើ ។
- មែកឈើអាចពណ៌នាអំពីវិស័យទាំងមូល សម្រាប់ក្រុមជួយខ្លួនឯង ។ កិច្ចការផ្សេងៗគ្នា អាចត្រូវបានបង្ហាញនៅក្នុងមែកឈើដាច់ដោយឡែកៗពីគ្នា ដូចជាការផ្តល់អំណាច តាមរយៈការបណ្តុះបណ្តាល និង ការអភិវឌ្ឍសហគ្រាសរបស់ស្ត្រីនៅក្នុងភូមិ ។ កម្មវិធីទាំងពីរនេះមានសាខារង ដែលកើតចេញមកពីសាខាចម្បងៗ នៃការផ្តល់អំណាច ។
- ស្លឹកគឺជាកម្មវិធីរៀបចំថវិកា ឬអន្តរាគមន៍លើព្រំដែននៃពេលវេលា ។ មានកម្មវិធីផ្សេងៗទៀត ដូចជាមជ្ឈមណ្ឌលប្រឹក្សាយោបល់សម្រាប់ស្ត្រី ផ្នែកកសិដ្ឋានដាំបន្លែសម្រាប់ស្ត្រី ដែលអាចធ្វើបាន។
- ផ្លែឈើ ជាលទ្ធផលវិជ្ជមាន ដែលបានរំពឹងទុកពីលំហាត់អនុវត្តន៍ ។ ផ្លែឈើទាំងនេះ នឹងលើកទឹកចិត្តដល់សហគមន៍ ឱ្យធ្វើការងាររួមគ្នា ។ ឧទាហរណ៍នេះ បង្ហាញអំពីសហគ្រាសរបស់ស្ត្រីដែលមានភាពរឹងមាំ ដូចគ្នានឹងមជ្ឈមណ្ឌលស្ត្រី ដែលផ្តល់ជម្រើសដល់ស្ត្រី ដើម្បីស្នាក់នៅក្នុងភូមិ ជាជាងបញ្ជូនពួកគេឱ្យចេញទៅរស់នៅខាងក្រៅ ។

## ជំហានទី ៦

### ការវិភាគលើនិន្នាការ : យល់អំពីស្ថានភាព និង ឥទ្ធិពលបច្ចុប្បន្នរបស់យើង

នេះជាប់ទាក់ទងទៅនឹងការធ្វើអត្ថាធិប្បាយអំពីព្រឹត្តិការណ៍បច្ចុប្បន្ន ឬក៏អាចសំដៅលើវិស័យព័តិមានជាក់ស្តែង ដូចជា ការប្រើប្រាស់ធនធានសំខាន់ៗ រួមមាន ដីធ្លី ឬ ទឹកនៅក្នុងភូមិ។

- ផ្តល់ជញ្ជាំងធំៗ ឬ ផ្តល់ឱ្យគូសលើដី ឬ លើក្រណាត់ ដែលអាចសរសេរ/គូរជាដ្យាក្រាម និន្នាការ ។ ដ្យាក្រាម និន្នាការ ជាជំនួយក្នុងការវិភាគ ។
- ជម្រាបជូនដល់ក្រុមទាំងអស់ឱ្យបានដឹងថា កិច្ចការរបស់គេ គឺបង្កើតនិន្នាការមួយនៃនិន្នាការទាំងអស់ ដែលកំពុងប៉ះពាល់ដល់យើង ក្នុងពេលនេះ។
- សូមពន្យល់ថា ម្នាក់ៗអាចដាក់ឈ្មោះនៃបញ្ហា និង ការសម្រេចចិត្តទៅលើទីតាំង ដែលត្រូវសរសេរលើដ្យាក្រាម។
- និយាយថាតើមានបញ្ហាអ្វីខ្លះ អ្នកណាខ្លះដែលរងផលប៉ះពាល់ តើអ្នកដែលរងផលប៉ះពាល់កំពុងរស់នៅទីណាខ្លះ តើពួកគេរងផលប៉ះពាល់យ៉ាងដូចម្តេច ហើយតើលោក-អ្នកនឹងដោះស្រាយបញ្ហាទាំងនោះ ដូចម្តេចដែរ?
- គូសរង្វង់មួយនៅចំចំណុចកណ្តាល រួចសរសេរអំពីមូលបទនៃដំណើររឿង/បញ្ហា ដែលត្រូវពិនិត្យស្វែងយល់ ក្នុងការដោះស្រាយ ។
- ស្នើសុំឱ្យអ្នកចូលរួមចាប់ផ្តើមសរសេរបញ្ហា និង និន្នាការ ពីឆ្វេងទៅស្តាំ ម្តងមួយៗ ។ អ្នកទី ១ ចាប់ផ្តើមពីទីតាំងនៃទ្រនិចនាឡិកាចង្អុលម៉ោង ១ ។ គាត់ត្រូវកំណត់នូវពាក្យ " អ្វី" "ដូចម្តេច" និង " ទីណា" នៃបញ្ហា និង ដំណោះស្រាយ ដោយផ្តល់ជាអនុសាសន៍ ក្នុងការដោះស្រាយសម្រាប់ថ្ងៃនេះ ព្រមទាំងបញ្ជាក់ថា តើគាត់នឹងត្រូវចូលរួមយ៉ាងដូចម្តេច ក្នុងដំណោះស្រាយលើបញ្ហានេះ ។
- មនុស្សម្នាក់ទៀតអាចចូលរួមបន្ថែមលើបញ្ហា និងថែមនិន្នាការថ្មីៗទៀត។
- និន្នាការដែលទាក់ទងដទៃទៀត ដូចជា ប្រភពទឹកផឹកដែលមានស្រាប់អាចត្រូវបានពិនិត្យ ផងដែរ។
- មនុស្សម្នាក់ៗក្នុងក្រុម ត្រូវសរសេរនូវនិន្នាការខាងក្រៅ ដែលប៉ះពាល់ដល់មូលបទនៃក្តីបារម្ភធនធានសម្រាប់ធ្វើការដោះស្រាយបញ្ហា និងប្រព័ន្ធអភិបាលកិច្ចដែលពាក់ពន្ធ័នានា។
- លើកទឹកចិត្តឱ្យសរសេរបានច្រើនគ្នា នៅលើដ្យាក្រាមនិន្នាការ នូវអ្វីដែលគេគិតថាវាមានសារៈសំខាន់ ។
- កិច្ចការសំខាន់ដែលម្នាក់ៗនឹងធ្វើ បានញ៉ាំងឱ្យមនុស្សដទៃមានការប្តូរផ្តាច់ទៅលើការងារ។
- ក្រោយពីកិច្ចការចប់សព្វគ្រប់ សូមលៃលកទុកពេល ដើម្បីឱ្យប្រជាជនបានអាន នូវអ្វីដែលបានសរសេរនៅលើផែនទី ។

- ដោយអ្នកខ្លះពុំចេះអានបាននោះ តម្រូវឱ្យមានក្រុមពិភាក្សា ដើម្បីឱ្យអ្នកភូមិអាចយល់បានទាំងអស់គ្នា នូវរាល់និន្នាការទាំងអស់ ក៏ដូចជា និន្នាការរួមក្នុងភូមិ ផងដែរ ។




ដ្យាក្រាមនិន្នាការ

Trend Diagram

ម៉ាទ្រិចនេះ បង្ហាញអំពីទំនាក់ទំនងដែលមានស្រាប់ និង គម្លាតពីគ្នាទៅវិញទៅមក ។ លោក-អ្នកអាចចាប់ផ្តើមពិភាក្សាដោយសួរថា តើនរណាជាអ្នកមានឥទ្ធិពល ហើយហេតុអ្វី? ។ វាមានសារៈប្រយោជន៍ ក្នុងការស្គាល់ អំពីស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ប្រជាជន ឬសហគមន៍ និង ទំនាក់ទំនងរវាងក្រុម និង ប្រជាជន ដើម្បីធ្វើផែនការឱ្យបានកាន់តែល្អប្រសើរឡើង ។ ការវិភាគជាបន្តបន្ទាប់ទៀតអាចបូកបញ្ចូល ដោយសួរថា តើនរណាត្រូវបានគេជ្រើសរើស ហើយហេតុអ្វី? ការវិភាគនេះនឹងជួយឱ្យលោក-អ្នក ក្នុងការកសាងការយោគយល់គ្នាជាលក្ខណៈសមូហភាព ស្តីអំពីការចូលរួមរបស់ប្រជាជន និង កសាងទំនាក់ទំនងគ្នាទៅវិញទៅមក រវាងក្រុមប្រជាជន និងតំណាងដែលបានជ្រើសរើស ។

## ការធ្វើផែនការតាមវិស័យ : ធ្វើផែនការដែលក្រុមចង់បាន ស្តីពីបញ្ហាផ្សេងៗ

បញ្ហានេះ មានសារៈសំខាន់ក្នុងជំហានទី ៦ និងជំហានទី ៨។ ផែនការសម្រាប់វិស័យនីមួយៗ ចាំបាច់ត្រូវធ្វើការកត់ត្រា ហើយការទទួលខុសត្រូវនានា ទាមទារឱ្យធ្វើការបែងចែក និង ទទួលយកឱ្យបានច្បាស់លាស់ ។ នៅពេលផែនការ ត្រូវបានលើកឡើង នៅក្រុមប្រឹក្សាភូមិ Panchayat គួរតប្បីពិនិត្យមើលឡើងវិញ ថាតើប្រជាជនដែលត្រូវធ្វើផែនការ ពិតជាបានធ្វើពិតប្រាកដមែន ។ ប្រសិនបើ ពួកគាត់បានធ្វើ តើធនធាន និងពេលវេលា ។ល។ មានគ្រប់គ្រាន់ ដែរឬទេ? ។

- បែងចែកអ្នកដែលចូលរួមចេញជាក្រុមចម្រុះមួយ ដោយឱ្យគាត់រាប់ ១-២-៣ និងបន្ទាប់មកបង្កើតក្រុមឡើងវិញ ដូចជាក្រុមទី ១ ក្រុមទី ២ និង ក្រុមទី ៣
- ទុកពេលជូនចំនួន ២ ម៉ោង សម្រាប់ក្រុមនីមួយៗ ដើម្បីរៀបចំគំនិតរបស់គេ សម្រាប់ពេលអនាគត
- ពន្យល់ថាភារកិច្ចក្រុម គឺធ្វើការបង្ហាញសម្រាប់មួយឆ្នាំខាងមុខ ដោយគិតចាប់ពីពេលនេះទៅ និងធ្វើការពន្យល់ អំពីឧបសគ្គនានាដែលគេត្រូវជំនះពុះពារឱ្យបាន
- លើក្រដាស សូមសរសេរ អំពីឧបសគ្គចម្បងៗដែលបានពុះពារ និងឱកាសនានា ដែលបានផ្តល់ឱ្យ
- ម្នាក់ៗត្រូវរៀបចំបញ្ជីស្តីអំពីសមិទ្ធផល ដែលទទួលបាន ក្រោយពីការបំពេញការងារជាមួយគ្នាបានរយៈពេលមួយឆ្នាំ ដោយផ្តល់ឧទាហរណ៍ច្បាស់លាស់ដូចជា តាមផ្ទះនីមួយៗក្នុងភូមិ មានក្បាលម៉ាស៊ីនទឹកមួយ ដែលអាចបើកទឹកបានយ៉ាងហោចណាស់ ៤ ម៉ោង ក្នុងមួយថ្ងៃ ។

តាមរយៈកិច្ចការនេះ ទស្សនវិស័យអនាគត សម្រាប់មួយឆ្នាំក្រោយទៀត នឹងរៀបទៅជាលក្ខណៈក្រាហ្វិក លើតារាង បើសិនជាមានការផ្លាស់ប្តូរ ។

ឥឡូវនេះ ចូរប្រើទស្សនវិស័យ នៃកិច្ចការដែលបានបំពេញនីមួយៗ ដើម្បីធ្វើការបំបែកចេញ ជាជំហានៗ ថា តើអាចបំពេញការងាររួចនៅពេលណា និង អ្នកណាត្រូវធ្វើអ្វីខ្លះ ព្រមទាំងរាយការណ៍ជូនអង្គសន្និបាតភូមិ នៅពេលណា? ។

## ជំហានទី ៧ និង ទី ៨

### ការពិភាក្សាក្រុមធំ : ដើម្បីឱ្យប្រជាជនយល់ពីទស្សនៈគ្នាទៅវិញទៅមក ឬ រួមគ្នាអនុម័តទៅលើស្ថានការណ៍នោះ

ការពិភាក្សាតាមក្រុមដោយបើកចំហធ្វើឡើង ដើម្បីសម្រេចចិត្ត ថាតើសកម្មភាពរួមគ្នាអាចត្រូវអនុវត្តបានយ៉ាងដូម្តេច ដោយផ្អែកទៅលើក្តារៀន ពីបទពិសោធន៏វិជ្ជមាននានាដែលមានពីមុន ។ ចំណុចផ្សេងៗដែលជួយ តម្រែតម្រង់ទិសដៅ សម្រាប់ការធ្វើផែនការមីក្រូ :

- ក្នុងករណីពុំមានការព្រមព្រៀងគ្នាកើតឡើង ភាគីពាក់ព័ន្ធត្រូវទទួលស្គាល់ការព្រមព្រៀងនោះ រួចហើយសរសេរបញ្ហាទាំងនោះ លើផ្ទាំងក្រដាស ។
- ចូរដាក់ផ្ទាំងក្រដាសនៅកន្លែងដែលអាចមើលឃើញ រួចដាក់បញ្ហាទាំងនេះ ដើម្បីជាលំហាត់ពិភាក្សា ហើយបន្តធ្វើការរិះរកដំណោះស្រាយ និង ធ្វើការពង្រឹងវេទិការួម ។

## ការពិភាក្សាជាក្រុមលើបញ្ហាអ្វីមួយ : ដើម្បីប្រមូលកម្លាំងប្រជាជនឱ្យគិតត្រិះរិះ លើបញ្ហាមួយឱ្យបានល្អិតល្អន់

រៀបចំការពិភាក្សាជាក្រុមតូច ដើម្បីឆ្លើយសំណួរជាក់លាក់ដូចជា :

- តើលោក-អ្នកមើលឃើញខ្លួនឯង និង ភូមិយ៉ាងដូចម្តេចខ្លះ បន្ទាប់ពីពេលជាក់លាក់មួយ?
- តើមានតម្រូវការចាំបាច់ចម្បងៗអ្វីខ្លះ សម្រាប់ការអភិវឌ្ឍ?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងដល់ការសម្រេចបាន លើតម្រូវការចាំបាច់ទាំងនោះ?
- តើសហគមន៏ និង ភូមិ Panchayat អាចធ្វើអ្វីបានខ្លះ?

វាអាចបង្កឱ្យមានគ្រោះថ្នាក់ ក្នុងការប្រើឧបករណ៍ តាមរបៀបតឹងរឹងពេក ។ លោក-អ្នកត្រូវចាំថា ការធ្វើផែនការមីក្រូ គឺជាដំណើរក្នុងការផ្តល់អំណាចដល់ប្រជាជន ដើម្បីធ្វើជាម្ចាស់លើធនធានក្នុងភូមិ និង រៀបចំផែនការ សម្រាប់ការលូតលាស់ប្រកបដោយនិរន្តរភាព ។ ដូចនេះ ការផ្តោតតែទៅលើការងារ អាចធ្វើឱ្យលោក-អ្នកឃ្លាតឆ្ងាយពីគោលបំណងស្នូល ក្នុងការបង្កើតរាល់កម្មសិទ្ធិភាពរួមទាំងអស់ និង ភាពចុះសម្រុងគ្នាក្នុងសង្គម ។ ធ្វើជាអ្នកផ្តួចផ្តើមក្នុងដំណើរការនេះ តម្រូវឱ្យលោក-អ្នកមានការឆ្លើយតបនឹងការផ្លាស់ប្តូរទៅតាមស្ថានភាព ដូចជាការរីកចម្រើននៃការរៀបចំផែនការ និង ការអនុវត្ត ជាដើម ។